អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

# សៀវភៅណែនាំ

# ស្តីពី

# ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ

## TAX CERTIFICATE MANAGEMENT SYSTEM

## មុខងារ៖ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

## TAX AGENT LICENSE

ជំនាន់. ១.២.០

២០២៣

សម្រាប់អ្នកជាប់ពន្ធ

www.tax.gov.kh

Call center: 1277

t.me/gdtcambodianews

www.youtube.com/@generaldepartmentoftaxation

រៀបចំដោយ៖ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

© រក្សាសិទ្ធិអគ្គនាយកដ្ឋានពន្ធដារ

# © រក្សាសិទ្ធិអ្នករៀបរៀង

សៀវភៅណែនាំស្តីពីការប្រើប្រាស់ **ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ មុខងារ៖ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ** គឺជាកម្មសិទ្ធិរបស់អគ្គនាយកដ្ឋានពន្ធដារ។ រាល់ការផលិត ឬថតចម្លងឡើងវិញនូវស្នាដៃនេះ ទោះបីទាំងស្រុងក្តី ឬជាភាគក្តី និងតាមរយៈការប្រើមធ្យោបាយណាក៏ដោយត្រូវបានហាមឃាត់ជាដាច់ខាត កាលបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសំណាក់អ្នករៀបរៀងទេនោះ។

ការបំពានលើសិទ្ធិអ្នករៀបរៀង គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវទទួលការផ្តន្ទាទោសពិន័យជាប្រាក់ និងដាក់ពន្ធនាគារដោយអនុលោមតាមច្បាប់ស្តីពីសិទ្ធិអ្នករៀបរៀង និងសិទ្ធិប្រហាក់ប្រហែល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ និងត្រូវផ្តន្ទាទោសឱ្យទទួលខុសត្រូវផ្នែករដ្ឋប្បវេណីចំពោះព្យសនកម្មដែលបានបង្កឡើង។

# អារម្ភកថា

វឌ្ឍនភាពនៃវិទ្យាសាស្ត្រ វិស្វកម្ម និងបច្ចេកវិទ្យា គឺជាគន្លឹះដ៏សំខាន់ក្នុងការជំរុញការផ្លាស់ប្ដូររបស់ពិភពលោក ឱ្យកាន់តែមានការរីកចម្រើនឥតឈប់ឈរជាលំដាប់។ បច្ចុប្បន្ននេះ ពិភពលោកកំពុងតែស្ថិតក្នុងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ ដែលផ្ដោតជាសំខាន់លើបរិវត្តកម្មឌីជីថល។ បច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកគាំទ្រ និងជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ជានាបាននូវកំណើន និងគុណភាពនៃផលិតកម្ម និងសេវាកម្ម ពង្រឹងបាននូវអភិបាលកិច្ចល្អ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព នៅក្នុងស្ថាប័ន និងបង្កើតឱ្យមាននូវនវានុវត្តន៍ថ្មីៗបន្ថែមទៀតដែលជាប្រយោជន៍ដល់ការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមជាតិ។ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (Information and Communication Technology) របស់រដ្ឋាភិបាលកម្ពុជា ដោយផ្ដោតសំខាន់លើវិធីសាស្ត្រនៃការគ្រប់គ្រង ការប្រើប្រាស់ឧបករណ៍ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន បានធ្វើឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ និងចាំបាច់ក្នុងការផ្ដល់សេវាកម្មសាធារណៈជូនប្រពលរដ្ឋ និងពង្រឹងអភិបាលកិច្ចល្អ ប្រកបដោយប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាព។ ផ្អែកទៅលើកាលានុវត្តភាពនេះ ព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងខិតខំស្វះស្វែង និងពុះពារគ្រប់ឧបសគ្គជាច្រើន ក្នុងការបង្កើត និងធ្វើទំនើបកម្មប្រព័ន្ធពន្ធដារឱ្យមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធគ្រប់ប្រភេទ សម្រាប់អភិវឌ្ឍប្រទេសជាតិស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យនៃការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។

អគ្គនាយកដ្ឋានពន្ធដារបានខិតខំអភិវឌ្ឍ ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមានមុខងារសំខាន់ក្នុងការគ្រប់គ្រងប្រមូលផ្ដុំទិន្នន័យនៃព័ត៌មានទាំងអស់ក្នុងប្រព័ន្ធតែមួយ (Centralized Database System) ដែលជួយសម្រួលដល់មន្ត្រីនិងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងការរៀបចំផែនការសកម្មភាពការងារ ការអនុវត្តការងារប្រចាំថ្ងៃ ការតាមដានត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ ការកំណត់បញ្ហានានា និងការស្វែងរកដំណោះស្រាយនៃបញ្ហា ក្នុងន័យជំរុញការងារប្រតិបត្តិស្នូល និងការងារគាំទ្រឱ្យប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ បន្ថែមលើនេះទៀត ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារបានជួយសម្រួលដល់មន្ត្រី និងថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការកាត់បន្ថយភាពស្មុគស្មាញនានាក្នុងការបំពេញបែបបទរដ្ឋបាល កាត់បន្ថយរយៈពេលនៃការបញ្ជូនឯកសារពីកម្រិតមន្ត្រី រហូតដល់ថ្នាក់ដឹកនាំ ផ្ដល់ភាពងាយស្រួលដល់ថ្នាក់ដឹកនាំ ក្នុងការគ្រប់គ្រងវាយតម្លៃប្រសិទ្ធភាពការងាររបស់មន្ត្រីក្រោមឱវាទ ក្នុងគោលបំណងធានាឱ្យបាននូវការបំពេញកាតព្វកិច្ចការងារក្នុងអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបានគោលដៅដែលបានកំណត់។

ដើម្បីជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមបច្ចេកវិទ្យាព័ត៌មាន ឱ្យបានលឿន និងកាន់តែមានប្រសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារបានរៀបចំ **សៀវភៅណែនាំស្ដីពីការប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ មុខងារ÷ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ** ដើម្បីឱ្យមន្ត្រី និងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ និងអ្នកជាប់ពន្ធអាចចូលទៅប្រើប្រាស់ ប្រព័ន្ធតាមវំហូរការងារ និងទាញយកទិន្នន័យមកប្រើប្រាស់ ប្រកបដោយជំនឿទុកចិត្ត គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព ដែលជាមូលដ្ឋានគ្រឹះនៃការជំរុញនិងលើកកម្ពស់កម្រិតសមត្ថភាពក្នុងការបំពេញការងារ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់ការណែនាំកម្រិតលម្អិតក្បោះក្បាយ និងច្បាស់លាស់ដល់អ្នកប្រើប្រាស់អំពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធ កម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជំរុញឱ្យការបំពេញភារៈកិច្ចឱ្យបានប្រសើរ ដោយផ្តល់ជូនអ្នកប្រើប្រាស់ នូវមុខងារមួយចំនួនដូចជា៖

1. បង្កើតគណនី e-Tax ថ្មី
2. បង្កើតពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារថ្មី បន្ត ព្យួរ ឬបច្ចុប្បន្នភាព
3. បញ្ជីព័ត៌មានស្នើសុំ
4. បោះពុម្ពវិញ្ញាបនបត្រអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងឈ្វេងយល់ពីការប្រើប្រាស់ ប្រព័ន្ធ-កម្មវិធីពន្ធដារ តាមរយៈឯកសារបណ្តុះបណ្តាលនានា ជាពិសេស សៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ នេះ ដើម្បីបង្កើនសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានកាន់តែប្រសើរឡើង ដែលជាការចូលរួមចំណែកមួយដ៏ធំធេង និងមានសារសំខាន់ក្នុងដំណើរការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាតិកា** ........................................................ **ទំព័រ**

**អារម្ភកថា** .......... ii

**ជំពូកទី១៖ ទិដ្ឋភាពទូទៅ** .......... 1

១.១ សេចក្តីផ្តើម .......... 1

១.២ វិសាលភាព .......... 1

១.៣ ប្រវត្តិកំណែប្រែ .......... 1

១.៤ សង្ខេបលំហូរនៃការប្រើប្រាស់កម្មវិធី .......... 1

**ជំពូកទី២៖ ការប្រើប្រាស់ប្រព័ន្ធ** .......... 2

២.១ តម្រូវការនៃការប្រើប្រាស់ប្រព័ន្ធ .......... 2

២.២ បង្កើតគណនីប្រើប្រាស់(User) .......... 2

២.៣ ការចូលប្រើប្រាស់ប្រព័ន្ធ .......... 4

២.៤ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ .......... 6

២.៤.១ សំណើសុំថ្មី .......... 6

២.៤.២ សំណើសុំបន្ត .......... 13

២.៤.៣ សំណើសុំព្យួរ .......... 15

២.៤.៤ សំណើសុំបច្ចុប្បន្នភាព .......... 17

២.៤.៥ បង់កម្រៃសេវាកម្មពន្ធដារ .......... 18

២.៤.៦ កែប្រែសំណើ .......... 19

២.៤.៧ លុបសំណើ .......... 20

៣.១.៤ បញ្ជីស្នើសុំ និងបោះពុម្ពអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ .......... 20

# ជំពូកទី១៖ ទិដ្ឋភាពទូទៅ

## ១.១ សេចក្តីផ្តើម

ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ មុខងារ៖ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធក្នុងការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ តាមរយៈអនឡាញ និងអាចបោះពុម្ពវិញ្ញាបនបត្រតាមអនឡាញដោយខ្លួនឯងបាន។

## ១.២ វិសាលភាព

ប្រព័ន្ធនេះមានវិសាលភាពប្រើប្រាស់សម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ។ ប្រព័ន្ធនេះមានមុខងារសំខាន់ៗដូចជា៖

- ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

## ១.៣ ប្រវត្តិកំណែប្រែ

| ល.រ | បរិយាយ | កាលបរិច្ឆេទ | ជំនាន់ |
|---|---|---|---|
| ១ | រៀបចំដំបូង | ១៨ សីហា ២០២៣ | ១.២.០ |

## ១.៤ សង្ខេបរំហូរនៃការប្រើប្រាស់កម្មវិធី




រូបភាពទី 1៖ រំហូរនៃការប្រើប្រាស់ប្រព័ន្ធ

## ជំពូកទី២៖ ការប្រើប្រាស់ប្រព័ន្ធ

### ២.១ តម្រូវការនៃការប្រើប្រាស់ប្រព័ន្ធ

- ✓ កុំព្យូទ័រ ដែលមានភ្ជាប់បណ្តាញ Internet ប្រទេសកម្ពុជា
- ✓ កម្មវិធី Web Browser ដូចជា Google Chrome ឬ Mozilla Firefox ជំនាន់ចុងក្រោយ
- ✓ អាសយដ្ឋានចូលប្រើប្រាស់ប្រព័ន្ធ https://www.tax.gov.kh
- ✓ គណនី (E-mail និងពាក្យសម្ងាត់) អាចបង្កើតបានដោយខ្លួនឯងតាមអាសយដ្ឋានខាងលើ
- ✓ សូមអនុញ្ញាតឱ្យផ្ទាំង pop-up ដំណើរការបាន (Allowed pop-up)

1. របៀបដោះ Popup តាមរយៈ Browser Firefox: សូមវាយពាក្យខាងក្រោមនៅប្រអប់អាសយដ្ឋាន៖

   **about:preferences#privacy**

   Scroll ចុះមកក្រោមដល់ចំណុច 

 **សូមដោះធីកចេញ**ជាការស្រេច។

2. របៀបដោះ Popup តាមរយៈ Browser Chrome: សូមវាយពាក្យខាងក្រោមនៅប្រអប់អាសយដ្ឋាន

   **chrome://settings/content/popups**

   សូមចុច Clickសញ្ញា  ដើម្បី **Allowed pop-up** ។

### ២.២ បង្កើតគណនីប្រើប្រាស់(User)

ប្រសិនបើលោក លោកស្រីមិនទាន់មានគណនីចូលប្រើប្រាស់ប្រព័ន្ធទេសូមចូលទៅបង្កើតគណនេយ្យថ្មី ដោយចុចលើតំណភ្ជាប់បង្កើតគណនេយ្យថ្មី ប្រព័ន្ធនឹងចេញផ្ទាំងសម្រាប់បញ្ចូលព័ត៌មានគណនេយ្យរបស់លោក លោកស្រី ដូចជា៖

- នាមត្រកូលជាអក្សរខ្មែរ
- នាមខ្លួនជាអក្សរខ្មែរ
- នាមត្រកូលជាអក្សរឡាតាំង
- នាមខ្លួនជាអក្សរឡាតាំង
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- លេខទូរស័ព្ទ
- អ៊ីម៉ែល (សម្រាប់ចូលប្រើប្រព័ន្ធ និងមិនអាចកែប្រែបានទេ)
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (មិនអាចកែប្រែបានទេ)
- សញ្ជាតិ
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (ITD) (មិនតម្រូវ)
- ប្រភេទអ្នកប្រើប្រាស់
- លេខអាជ្ញាប័ណ្ណ (នៅពេលជ្រើសរើសភ្នាក់ងារសេវាកម្មពន្ធដារ)
- ធីកធានាអះអាង

- បំពេញ CAPTCHA
- ចុចប៊ូតុងបន្ទាប់

ប្រព័ន្ធនឹងផ្ញើសារជាលីងទៅកាន់អ៊ីម៉ែលរបស់លោក លោកស្រី និងចេញផ្ទាំងផ្ទៀងផ្ទាត់អ៊ីម៉ែលបើសិនជាលោក លោកស្រីមិនឃើញ អ៊ីម៉ែលដែលប្រព័ន្ធផ្ញើទៅទេ សូមចុចតំណភ្ជាប់ផ្ញើម្តងទៀត បន្ទាប់មកសូមធ្វើតាមសេចក្តីណែនាំក្នុងសារអេឡិកត្រូនិចរបស់លោក លោកស្រី ប្រព័ន្ធនឹងឱ្យលោក លោកស្រីបញ្ចូលពាក្យសម្ងាត់ថ្មី ដូចលំនាំខាងក្រោម៖




រូបភាពទី 2៖ បង្កើតអ្នកប្រើប្រាស់

## ២.៣ ការចូលប្រើប្រាស់ប្រព័ន្ធ

លោក លោកស្រីសូមចូលទៅកាន់តំណភ្ជាប់: https://owp.tax.gov.kh/gdtowpcoreweb/login

លោក លោកស្រីអាចចូលប្រើប្រព័ន្ធបាន បីប្រភេទ៖

- តាមរយៈ MOI ID
  - សូមចុចលើ MOI ID
  - បញ្ចូលលេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- តាមរយៈអ៊ីម៉ែល
  - សូមចុចលើអ៊ីម៉ែល
  - បញ្ចូលអ៊ីម៉ែល
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- តាមរយៈ TID
  - សូមចុចលើ TID
  - សូមបញ្ចូលលេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID)
  - បញ្ចូលពាក្យសម្ងាត់
  - ចុចប៊ូតុងចូលប្រើប្រព័ន្ធ
- ចុចលើរូបប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ
- ចុះឈ្មោះសហគ្រាសស្នើសុំវិញ្ញាបនបត្រពន្ធដារ
  - បញ្ចូល IP Address ដែលបានទទួលពីក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេត ឬចុចប៊ូតុង Get IP
  - បញ្ចូលលេខអត្តសញ្ញាណកម្មសារពើពន្ធ (បញ្ចូលលេខ អតប)
  - បញ្ចូលលេខកាតសម្គាល់ការចុះបញ្ជីពន្ធដារ (TID)
  - បញ្ចូលលេខទូរស័ព្ទម្ចាស់ភាគហ៊ុនឈរឈ្មោះលើប័ណ្ណប៉ាតង់ រួចចុចប៊ូតុង បន្ទាប់
  - សូមបញ្ចូលលេខកូដដែលបានផ្ញើទៅកាន់ទូរសព្ទដៃ របស់ម្ចាស់ភាគហ៊ុនឈរឈ្មោះលើប័ណ្ណប៉ាតង់ រួចចុចប៊ូតុង ផ្ទៀងផ្ទាត់
- បញ្ជីសហគ្រាស
  - សូមស្វែងរកសហគ្រាសតាមរយៈការបញ្ចូលលេខអត្តសញ្ញាណសារពើពន្ធ រួចចុចលើប៊ូតុងស្វែងរក ប្រព័ន្ធនឹងបង្ហាញនូវព័ត៌មានអំពីសហគ្រាសដែលបានស្នើសុំ រួចចុចលើប៊ូតុង ស្នើសុំ
- ចុចលើរូបប្រព័ន្ធស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដូចលំនាំខាងក្រោម ៖


ប្រព័ន្ធគ្រប់គ្រង e-Tax
ប្រព័ន្ធគ្រប់គ្រងគណនីអ្នកប្រើប្រាស់
ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម
បញ្ជីលក់អេឡិចត្រូនិក (e-VAT)
ប្រព័ន្ធគ្រប់គ្រងការស្នើសុំ DTA
បង់ពន្ធសហគ្រាស


ប្រព័ន្ធគ្រប់គ្រង e-Tax > ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ
ចុះឈ្មោះស្នើសុំវិញ្ញាបនបត្រពន្ធដារ
ADDRESS IP *
Get IP
លេខអត្តសញ្ញាណកម្មសារពើពន្ធ *
ឧទាហរណ៍៖ 208977123
GDTREG
ឧទាហរណ៍៖ 000097877
ឧទាហរណ៍៖ 012 123 324
បន្ទាប់


ប្រព័ន្ធគ្រប់គ្រង e-Tax > ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ
ចុះឈ្មោះស្នើសុំវិញ្ញាបនបត្រពន្ធដារ / ផ្ទៀងផ្ទាត់
បញ្ចូលលេខកូដ *
ឧទាហរណ៍: 123456
ផ្ទៀងផ្ទាត់
មិនទាន់បានទទួលអ៊ីម៉ែល?
ផ្ញើសារម្តងទៀត




រូបភាពទី 1៖ មុខងារស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

## ២.៤ ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

សូមលោក លោកស្រីចុចលើ Logo ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ៖




រូបភាពទី 2៖សុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

### ២.៤.១ សំណើសុំថ្មី

សូមលោក លោកស្រីចុចលើប៊ូតុង**សំណើសុំថ្មី** ករណីសហគ្រាសមិនដែលធ្លាប់សុំ ដូច្នេះពេលចូលមកដំបូង ប្រព័ន្ធបង្ហាញផ្ទាំងឱ្យបញ្ចូលព័ត៌មានបង្កើតសំណើមាន ៥ ជំហាន៖

១. ពិនិត្យព័ត៌មានអ្នកស្នើសុំ រួចចុចប៊ូតុងបន្ទាប់

២. ពិនិត្យព័ត៌មានសហគ្រាសស្នើសុំ រួចចុចប៊ូតុងបន្ទាប់

៣. ព័ត៌មានអ្នកឈរឈ្មោះអាជ្ញាប័ណ្ណ សូមជ្រើសរើសឈ្មោះអ្នកឈរឈ្មោះ ជ្រើសរើសលក្ខខណ្ឌ៖

- **ករណីអតីតមន្ត្រីពន្ធដារ** សូមបញ្ចូលអត្តលេខពន្ធដារ និងអត្តលេខមន្ត្រីរាជការ ចុចប៊ូតុងស្វែងរក

- **ករណីគណនេយ្យករ និងសវនករជំនាញដែលជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា** សូមបញ្ចូលសមាជិកភាពលេខ កាលបរិច្ឆេទចូលជាសមាជិក និងដាក់ឯកសារ រួចចុចប៊ូតុងបន្ទាប់
- **រូបវន្តបុគ្គលដែលបានប្រឡងជាប់ជំនាញវិជ្ជាជីវពន្ធដារ** សូមបញ្ចូលលេខវិញ្ញាបនបត្រជំនាញវិជ្ជាជីវពន្ធដារ រួចប៊ូតុងស្វែងរក
- **ក្រុមហ៊ុននីតិបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិដែរទទួលបានអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យ និងសវនកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** សូមបញ្ចូលអាជ្ញាប័ណ្ណលេខ កាលបរិច្ឆេទអាជ្ញាប័ណ្ណ និងដាក់ឯកសារ រួចចុចប៊ូតុង**បន្ទាប់**

៤. ព័ត៌មានបុគ្គលិក សូមចុចប៊ូតុង **បន្ថែមបុគ្គលិកថ្មី** ដោយស្វែងរកតាមរយៈលេខ TID NID ឬ លេខលិខិតឆ្លងដែន បញ្ចូលថ្ងៃចូលបំរើការងារ និងអត្តលេខសិស្សសាលាជាតិពន្ធដារ រួចចុចប៊ូតុង**ស្វែងរក** ករណីមិនមានព័ត៌មាន ប្រព័ន្ធនឹងចេញឱ្យលោក លោកស្រីបំពេញព័ត៌មានរូបវន្តបុគ្គល បន្ទាប់មកចុចប៊ូតុងរក្សាទុក រួចចុចប៊ូតុង**បន្ទាប់**

៥. សូមពិនិត្យ និងផ្ទៀងផ្ទាត់ ព័ត៌មានការស្នើសុំ សូមចុចប៊ូតុង**រក្សាទុកជាពង្រាង** ករណីលោក លោកស្រីមិនទាន់ដាក់ពាក្យនិងបង់សេវា សូមចុចប៊ូតុង**ដាក់ពាក្យស្នើសុំ និងបង់កម្រៃសេវាកម្មពន្ធដារ** ប្រព័ន្ធនឹងចេញផ្ទាំងកម្មវិធីធនាគារ សូមធ្វើការបង់កម្រៃ ដូចលំនាំខាងក្រោម៖




ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ V1.1.10
ត្រឡប់
ទំព័រដើម
បញ្ជីការស្នើសុំ
បោះពុម្ពលិខិតជូនដំណឹង
ស្នើសុំថ្មី / ជំហានទី២ - ព័ត៌មានសហគ្រាសស្នើសុំ
ព័ត៌មានអ្នកស្នើសុំ
ព័ត៌មានសហគ្រាសស្នើសុំ
ព័ត៌មានអ្នកឈរឈ្មោះលើអាជ្ញាប័ណ្ណ
បញ្ជីព័ត៌មានបុគ្គលិក
ពិនិត្យ និងផ្ទៀងផ្ទាត់
លេខអត្តសញ្ញាណកម្មសារពើពន្ធ : L001-104000899
ឈ្មោះសហគ្រាសជាអក្សរខ្មែរ : ក្រុមហ៊ុនជេជេប៊ីអាយអាយអេអេហ្វខូអិលធីឌី
ឈ្មោះសហគ្រាសជាអក្សរឡាតាំង : JJBIIAF Company Co.,Ltd
អាសយដ្ឋាន : ផ្ទះលេខ ផ្លូវសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ប្រភេទអ្នកជាប់ពន្ធ : ពន្ធធំ
ស្ថិតក្រោមការគ្រប់គ្រងរបស់ : នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
សកម្មភាពអាជីវកម្ម : ៤៩២៣០ - សេវាដឹកជញ្ជូនអ្នកដំណើរ
ស្ថានភាពស្នើសុំ : កំពុងដំណើរការអាជីវកម្ម
សូមធីក ករណីព័ត៌មានរបស់លោក លោកស្រីពិតជាត្រឹមត្រូវ។
ត្រលប់
បន្ទាប់


ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ V1.1.10
ត្រឡប់
ទំព័រដើម
បញ្ជីការស្នើសុំ
បោះពុម្ពលិខិតជូនដំណឹង
ស្នើសុំថ្មី / ជំហានទី៣ - ព័ត៌មានអ្នកឈរឈ្មោះលើអាជ្ញាប័ណ្ណ
ព័ត៌មានអ្នកស្នើសុំ
ព័ត៌មានសហគ្រាសស្នើសុំ
ព័ត៌មានអ្នកឈរឈ្មោះលើអាជ្ញាប័ណ្ណ
បញ្ជីព័ត៌មានបុគ្គលិក
ពិនិត្យ និងផ្ទៀងផ្ទាត់
គោត្តនាម និងនាម : សុខ រ៉ចង់ 1760
លេខអត្តសញ្ញាណប័ណ្ណ : 900001760
តួនាទី : ប្រធានក្រុមប្រឹក្សាភិបាល
កាន់កាប់ភាគហ៊ុន : 100%
សញ្ជាតិ : ខ្មែរ
ភេទ : ប្រុស
លេខទូរស័ព្ទ : 055998877
សារអេឡិចត្រូនិក : sokromchong4890@gmail.com
តើលោក លោកស្រីមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមក្នុងការស្នើសុំ?
អតីតមន្ត្រីពន្ធដារ
គណនេយ្យករ និងសវនករជំនាញដែលជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា
រូបវន្តបុគ្គលដែលបានប្រឡងជាប់ជំនាញវិជ្ជាជីវៈពន្ធដារ
ក្រុមហ៊ុននីតិបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិដែរទទួលបានអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យ និងសវនកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ករណីលោក លោកស្រី ធ្លាប់បានបម្រើការងារនៅនាយកដ្ឋាន/សាខាពន្ធដារ សូមបំពេញព័ត៌មានដូចខាងក្រោម៖
អត្តលេខពន្ធដារ
1586
អត្តលេខមន្ត្រីរាជការ
1581200058
ស្វែងរក
គោត្តនាម និងនាម : ឡុញ វណ្ណា
ភេទ : ប្រុស
អត្តលេខមន្ត្រីរាជការ : 1581200058
អត្តលេខពន្ធដារ : 1586
នាយកដ្ឋាន/សាខាពន្ធដារ : នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
តួនាទីចុងក្រោយ : មន្ត្រី
រយៈពេលចូលបម្រើការងារ : 30ឆ្នាំ
សូមធីក ករណីព័ត៌មានរបស់លោក លោកស្រីពិតជាត្រឹមត្រូវ។
ត្រលប់
បន្ទាប់








បញ្ជាក់
ការស្នើសុំរបស់លោក លោកស្រីត្រូវបានរក្សាទុករួចរាល់ សូមចូលទៅកាន់បញ្ជីស្នើសុំដើម្បីពិនិត្យព័ត៌មានលម្អិត។
យល់ព្រម
PAYMENT INFORMATION
Ref ID: 202308181500042992
Amount: 2000000 KHR
Short Desc: TAX PAYMENT
Total: 2000000 KHR
CHOOSE PAYMENT OPTION
Canadia Bank Account
Debit/Credit Card
Continue
We have sent a sms to your phone number
OTP will be expired within 3 minute
Submit
Fee: 4000 KHR
Payment successfully



បោះពុម្ព

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

OATG2023000032

**លិខិតបញ្ជាក់**
**ការបង់ប្រាក់ស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ**

| | |
|---|---|
| លេខអត្តសញ្ញាណកម្មសារពើពន្ធ | ៖K005-105009393 |
| ឈ្មោះសហគ្រាសជាអក្សរខ្មែរ | ៖ក្រុមហ៊ុនជេជេស៊ីជេអេចជេអេហ្វខូអិលធីឌី |
| ឈ្មោះសហគ្រាសជាអក្សរឡាតាំង | ៖JJCJHJF Company Co.,Ltd |
| សកម្មភាពអាជីវកម្ម | ៖បញ្ជូន និងចែកចាយថាមពលអគ្គិសនី |
| ស្ថិតក្រោមការគ្រប់គ្រងរបស់ | ៖សាខាពន្ធដារខណ្ឌទួលគោក |
| ប្រភេទអ្នកជាប់ពន្ធ | ៖ពន្ធមធ្យម |
| អាសយដ្ឋាន | ៖ផ្ទះលេខ១២ ផ្លូវ៥៩៨ ក្រុម ១៥ ភូមិ៣ សង្កាត់បឹងកក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| ប្រភេទស្នើសុំ | ៖ស្នើសុំបន្ត |
| ស្ថានភាពបង់កម្រៃភ្នាក់ងារ | ៖បានបង់ |
| ប្រាក់ពន្ធបានបង់ | ៖2,000,000 រៀល |
| ទឹកប្រាក់ពិន័យ | ៖0 រៀល |
| ការប្រាក់ | ៖0 រៀល |
| លេខប្រតិបត្តិការ | ៖ECAN2308181500042992 |
| កាលបរិច្ឆេទបង់ប្រាក់ | ៖ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ម៉ោង៣ ល្ងាច |

លោក លោកស្រីអាចប្រើប្រាស់ QR កូដនេះ
ដើម្បីតាមដានដំណើរការនៃការស្នើសុំនេះ
តាមរយៈកម្មវិធី GDT Check&Track

លោក លោកស្រីអាចទាញយក
កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ
(GDT Check & Track) នៅទីនេះ:

App Store

Play Store

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

× បោះបង់

បោះពុម្ព

រូបភាពទី 3៖សំណើសុំថ្មី

### ២.៤.២ សំណើសុំបន្ត

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីពាក្យស្នើសុំ** ករណីសហគ្រាសដែលបានសុំអាជ្ញាប័ណ្ណបានជោគជ័យ ដូច្នេះពេលចូលមកដំបូងប្រព័ន្ធបង្ហាញទិន្នន័យបានស្នើជោគជ័យ សូមចុចលើប៊ូតុង**ស្នើសុំបន្ត** ប្រព័ន្ធនឹងចេញផ្ទាំងឱ្យបញ្ចូលព័ត៌មានបង្កើតសំណើមាន ៥ ជំហាន៖

១. ពិនិត្យព័ត៌មានអ្នកស្នើសុំ រួចចុចប៊ូតុងបន្ទាប់

២. ពិនិត្យព័ត៌មានសហគ្រាសស្នើសុំ រួចចុចប៊ូតុងបន្ទាប់

៣. បន្តសុពលភាព ចុចប៊ូតុង**បន្ទាប់**

៤. ព័ត៌មានបុគ្គលិក សូមចុចប៊ូតុង **បន្ថែមបុគ្គលិកថ្មី** ដោយស្វែងរកតាមរយៈលេខ TID NID ឬ លេខលិខិតឆ្លងដែន បញ្ចូលថ្ងៃចូលបំរើការងារ និងអត្តលេខសិស្សសាលាជាតិពន្ធដារ រួចចុចប៊ូតុង**ស្វែងរក** ករណីមិនមានព័ត៌មាន ប្រព័ន្ធនឹងចេញឱ្យលោក លោកស្រីបំពេញព័ត៌មានរូបវន្តបុគ្គល បន្ទាប់មកចុចប៊ូតុងរក្សាទុក រួចចុចប៊ូតុង**បន្ទាប់**

៥. សូមពិនិត្យ និងផ្ទៀងផ្ទាត់ ព័ត៌មានការស្នើសុំ សូមចុចប៊ូតុង**រក្សាទុកជាពង្រាង** ករណីលោក លោកស្រីមិនទាន់ដាក់ពាក្យនិងបង់សេវា សូមចុចប៊ូតុង**ដាក់ពាក្យស្នើសុំ និងបង់កម្រៃសេវាកម្មពន្ធដារ** ប្រព័ន្ធនឹងចេញផ្ទាំងកម្មវិធីធនាគារ សូមធ្វើការបង់កម្រៃ ដូចលំនាំខាងក្រោម៖






រូបភាពទី 3៖សំណើសុំបន្ត

### ២.៤.៣ សំណើសុំព្យួរ

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីពាក្យស្នើសុំ** ករណីសហគ្រាសដែលបានសុំអាជ្ញាប័ណ្ណបានជោគជ័យ ដូច្នេះពេលចូលមកដំបូងប្រព័ន្ធបង្ហាញទិន្នន័យបានស្នើជោគជ័យ សូមចុចលើប៊ូតុង**ស្នើសុំព្យួរ** ប្រព័ន្ធនឹងចេញផ្ទាំងឱ្យបញ្ចូលព័ត៌មានបង្កើតសំណើមាន ៥ ជំហាន៖

១. ពិនិត្យព័ត៌មានអ្នកស្នើសុំ រួចចុចប៊ូតុងបន្ទាប់

២. ពិនិត្យព័ត៌មានសហគ្រាសស្នើសុំ រួចចុចប៊ូតុងបន្ទាប់

៣. ព្យួរអាជ្ញាប័ណ្ណ សូមបញ្ចូលរយៈពេលព្យួរ និងមូលហេតុ រួចចុចប៊ូតុង**បន្ទាប់**

៤. ព័ត៌មានបុគ្គលិក សូមចុចប៊ូតុង **បន្ថែមបុគ្គលិកថ្មី** ដោយស្វែងរកតាមរយៈលេខ TID NID ឬ លេខលិខិតឆ្លងដែន បញ្ចូលថ្ងៃចូលបំរើការងារ និងអត្តលេខសិស្សសាលាជាតិពន្ធដារ រួចចុចប៊ូតុង**ស្វែងរក** ករណីមិនមានព័ត៌មាន ប្រព័ន្ធនឹងចេញឱ្យលោក លោកស្រីបំពេញព័ត៌មានរូបវន្តបុគ្គល បន្ទាប់មកចុចប៊ូតុងរក្សាទុក រួចចុចប៊ូតុង**បន្ទាប់**

៥. សូមពិនិត្យ និងផ្ទៀងផ្ទាត់ ព័ត៌មានការស្នើសុំ សូមចុចប៊ូតុង**រក្សាទុកជាពង្រាង** ករណីលោក លោកស្រីមិនទាន់ដាក់ពាក្យ សូមចុចប៊ូតុង**ដាក់ពាក្យស្នើសុំ** ករណីចង់ដាក់ស្នើ ដូចលំនាំខាងក្រោម៖





រូបភាពទី 4៖សំណើសុំព្យួរ

### ២.៤.៤ សំណើសុំបច្ចុប្បន្នភាព

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីពាក្យស្នើសុំ** ករណីសហគ្រាសដែលបានសុំអាជ្ញាប័ណ្ណបានជោគជ័យ ដូច្នេះពេលចូលមកដំបូងប្រព័ន្ធបង្ហាញទិន្នន័យបានស្នើជោគជ័យ សូមចុចលើប៊ូតុង**ស្នើសុំបច្ចុប្បន្នភាព** ប្រព័ន្ធនឹងចេញផ្ទាំងឱ្យបញ្ចូលព័ត៌មានបង្កើតសំណើមាន ៥ ជំហាន៖

១. ជំហានទី១ ដល់ទី៤ ការប្រើប្រាស់ដូចការស្នើសុំថ្មីដែរ

៥. សូមពិនិត្យ និងផ្ទៀងផ្ទាត់ ព័ត៌មានការស្នើសុំ សូមចុចប៊ូតុង**រក្សាទុកជាពង្រាង** ករណីលោក លោកស្រីមិនទាន់ដាក់ពាក្យ សូមចុចប៊ូតុង**ដាក់ពាក្យស្នើសុំ** ករណីចង់ដាក់ស្នើ ដូចលំនាំខាងក្រោម៖



រូបភាពទី 5៖សំណើសុំបច្ចុប្បន្នភាព

### ២.៤.៥ បង់កម្រៃសេវាកម្មពន្ធដារ

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីការស្នើសុំ** ចុចលើប៊ូតុង **បង់កម្រៃសេវាភ្នាក់ងារ** សូមមើលលំនាំខាងក្រោម៖

**បញ្ជាក់៖** ករណីបង្កើតសំណើមិនទាន់ដាក់ពាក្យ និងបង់កម្រៃ




រូបភាពទី 6៖បង់កម្រៃសេវាកម្មពន្ធដារ

## ២.៤.៦ កែប្រែសំណើ

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីការស្នើសុំ** ចុចលើប៊ូតុង**កែប្រែ** ប្រព័ន្ធនឹងបង្ហាញផ្ទាំង៥ជំហាន សូមធ្វើការកែប្រែតាមជំហាននីមួយដូចការប្រើប្រាស់ពេលដែលបង្កើតថ្មីដែរ៖

**បញ្ជាក់៖**កែប្រែបានក្នុង ករណីមិនទាន់ដាក់ពាក្យស្នើសុំ និងបង់កម្រៃសេវា




រូបភាពទី 7៖ការកែប្រែសំណើ

### ២.៤.៧ លុបសំណើ

សូមលោក លោកស្រីចុចលើម៉ឺនុយ **បញ្ជីការស្នើសុំ** ចុចលើប៊ូតុង**លុប** សូមចុចប៊ូតុង**លុប៖ បញ្ជាក់៖**លុបបានក្នុង ករណីមិនទាន់ដាក់ពាក្យស្នើសុំ និងបង់កម្រៃសេវា




រូបភាពទី ៨៖លុបសំណើ

### ៣.១.៤ បញ្ជីស្នើសុំ និងបោះពុម្ពអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

សូមលោក លោកស្រីចុចបញ្ជីសំណើ រួចធ្វើការគណនាចំនួនថ្ងៃផ្អាកនៅសល់ គឺនៅពេលដែលមានការស្នើសុំត្រូវបានឯកភាពតែប៉ុណ្ណោះ ប្រសិនហួសកាលផុតកំណត់អនុញ្ញាតឱ្យផ្អាកដំណើរការអាជីវកម្ម នោះប្រព័ន្ធត្រូវកំណត់ស្ថានភាពទៅជា "កំពុងដំណើរការអាជីវកម្ម" សូមពិនិត្យប្រភេទស្នើសុំ ករណីបង្ហាញផ្អាកអាជីវកម្ម សូមចុចប៊ូតុងបោះពុម្ពលិខិតជូនដំណឹង រួចធ្វើការបោះពុម្ពលិខិតជូនដំណឹងស្តីពីការអនុញ្ញាតឱ្យផ្អាកដំណើរការសកម្មភាពជាបណ្តោះអាសន្ន ដូចលំនាំខាងក្រោម៖





បោះពុម្ព

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ CATG2023000003 អពដ

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**ជម្រាបជូន**
**លោក លោកស្រីនាយកសហគ្រាស**
**ក្រុមហ៊ុនជេជេអ៊ីអេចជីជេស៊ីខូអិលធីឌី**
JJEHGJC Company Co.,Ltd

**កម្មវត្ថុ** ៖ ករណីស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។
**យោង** ៖ - ប្រកាសលេខ ២៣០សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ស្ដីពីភ្នាក់ងារសេវាកម្មពន្ធដារ
- លិខិតស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ របស់សហគ្រាស **ក្រុមហ៊ុនជេជេអ៊ីអេចជីជេស៊ីខូអិលធីឌី** ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស សូមជម្រាបជូន លោក លោកស្រីដែលជានាយកសហគ្រាស ឱ្យបានជ្រាបថា សំណើនៃការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ របស់លោក លោកស្រីកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ត្រូវបានអគ្គនាយកដ្ឋានពន្ធដារ សម្រេចអនុញ្ញាតផ្ដល់ជូន។

ការអនុញ្ញាតផ្ដល់ជូននូវអាជ្ញាប័ណ្ណនេះ សហគ្រាសរបស់លោក លោកស្រីមានសិទ្ធិក្នុងការផ្ដល់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារជូនដល់អ្នកជាប់ពន្ធដូចជា ការចុះបញ្ជីពន្ធដារ ការប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ និងសេវាកម្មពាក់ព័ន្ធនឹងពន្ធដារផ្សេងទៀតបាន។ សម្រាប់ការបំពេញនូវការផ្ដល់សេវាកម្មពាក់ព័ន្ធនឹងពន្ធដាររបស់សហគ្រាសលោក លោកស្រីជូនដល់អ្នកជាប់ពន្ធត្រូវបានផ្សារភ្ជាប់ជាមួយសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

**១. សិទ្ធិ**(ជាភ្នាក់ងារសេវាកម្មពន្ធដារ)

បន្ថែមលើសិទ្ធិដែលមានចែងក្នុងមាត្រា១០៦ នៃច្បាប់ស្ដីពីសារពើពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារដែលមានលិខិតផ្ទេរសិទ្ធជាលាយលក្ខណ៍អក្សរធ្វើជាតំណាងស្របច្បាប់ពីអ្នកជាប់ពន្ធ មានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ
- បំពេញបែបបទពន្ធដារ

បោះពុម្ពដក Letter Head ចេញ ឬផ្ទៃខាងក្រោយ
ប្រើ Auto Signature
បោះបង់
បោះពុម្ព

រូបភាពទី ៩៖ បោះពុម្ពលិខិតជូនដំណឹង

# អគ្គនាយកដ្ឋានពន្ធដារ

## GENERAL DEPARTMENT OF TAXATION

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +855 23 886 708 / ទូរសារ៖ +855 23 886 700
សារអេឡិចត្រូនិក៖ gdt@tax.gov.kh / គេហទំព័រ៖ www.tax.gov.kh